ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល

THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ១០៦/១១-ហ៊ុង ឈើង

កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១១

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា៣១៣នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ យូ សួនទី

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ អាន វីរៈ

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ ប៉ែន ប៊ុនឈា

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ ក្រុមហ៊ុន ហ៊ុង ឈើង

អាសយដ្ឋាន ៖ ផ្លូវវែងស្រែង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០៩៧ ៦៤៣ ០៨ ០៨ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជក ៖ អវត្តមាន

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ - សហព័ន្ធសហជីពសម្ព័ន្ធកម្មករខ្មែរ

- សហជីពសម្ព័ន្ធកម្មករខ្មែរនៃរោងចក្រ ហ៊ុង ឈើង

អាសយដ្ឋាន ៖ ផ្លូវវែងស្រែង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០៩២ ៥០០ ៦៣៤ ទូរសារ ៖ គ្មាន

តំណាងកម្មករនិយោជិត:

១- លោក មុំ បូណា ប្រធានសហព័ន្ធសហជីពសម្ព័ន្ធកម្មករខ្មែរ

២- លោក ឡុង សេរី មន្ត្រីសហព័ន្ធសហជីពសម្ព័ន្ធកម្មករខ្មែរ



ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារៈ ៨៥៥-២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh• Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org• Website: www.arbitrationcouncil.org

## បញ្ហាក្តីវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- ទាមទារឱ្យក្រុមហ៊ុនទទួលយកថ្នាក់ដឹកនាំសហជីពសម្ព័ន្ធកម្មករខ្មែរចូលធ្វើការវិញ ។

២- ទាមទារឱ្យក្រុមហ៊ុនបញ្ឈប់ការកាត់ប្រាក់ឈ្នួលកម្មករទុកម្នាក់ចំនួន ១០ ដុល្លារ ។

៣- ស្នើឱ្យក្រុមហ៊ុនទទួលខុសត្រូវ នៅពេលកម្មករសន្លប់ និងគ្រោះថ្នាក់ការងារផ្សេងៗក្នុងក្រុមហ៊ុន ។

៤- ទាមទារឱ្យក្រុមហ៊ុនអនុញ្ញាតឱ្យកម្មករពាក់ស្បែកជើងចូលធ្វើការ ។

៥- ទាមទារឱ្យក្រុមហ៊ុនសងលុយចំនួន ៥ ដុល្លារ ដែលក្រុមហ៊ុនបានកាត់ពីកម្មករដែលមិនបានមកធ្វើការ នៅថ្ងៃអាទិត្យ ។

៦- ទាមទារឱ្យថ្នាក់ដឹកនាំរោងចក្រ និងចិនប្រើអាកប្បកិរិយាសមរម្យចំពោះកម្មករនិយោជិត ។

៧- ទាមទារមិនឱ្យក្រុមហ៊ុនកាត់ប្រាក់ឈ្នួលលើសថ្ងៃដែលកម្មករឈប់ឥតច្បាប់ ។

៨- សុំឱ្យមានបន្ទប់ពេទ្យ និងមានថ្នាំពេទ្យគ្រប់គ្រាន់ក្នុងរោងចក្រ ។

៩- ទាមទារឱ្យក្រុមហ៊ុនបើកប្រាក់ឈ្នួលនៅថ្ងៃទី០៥ ជារៀងរាល់ខែ ។

១០- ទាមទារឱ្យក្រុមហ៊ុនរៀបចំទារកដ្ឋានទៅតាមច្បាប់ស្តីពីការងារ ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែក ទីពីរ(ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៣៦ កប/ប្រក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១ (អាណត្តិទី៥) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ៩២៦ កប/អក/វក ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១១ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១១ ។

## សវនាការ និង សង្ខេបនីតិវិធី

ទីកន្លែងសវនាការ ៖ ក្រុមប្រឹក្សាអាជ្ញាកណ្តាល "ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី) សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ" ។

កាលបរិច្ឆេទសវនាការ ៖ ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១១ (វេលាម៉ោង ០៨៖៣០ នាទី ព្រឹក) ។

បញ្ហានៃនីតិវិធី ៖

នៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១១ នាយកដ្ឋានវិវាទការងារបានទទួលពាក្យបណ្តឹងរបស់សហព័ន្ធសហជីពសម្ព័ន្ធកម្មករខ្មែរលេខ ១៩/១១ សសសកខ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១ ស្តីពីការទាមទារឱ្យក្រុមហ៊ុនកែលំអលក្ខខណ្ឌការងារឱ្យបានល្អប្រសើរ។ បន្ទាប់មក នាយកដ្ឋានវិវាទការងារបានចាត់តាំងមន្ត្រីធ្វើការដោះស្រាយវិវាទការងាររួមនេះជាបន្តបន្ទាប់ និងធ្វើការផ្សះផ្សាចុងក្រោយ នៅថ្ងៃទី០២ ខែសីហា ឆ្នាំ២០១១ ដោយទទួលលទ្ធផលមិនសះជានឹងគ្នាចំនួន១០ចំណុច លើការទាមទារចំនួន១០ចំណុច ដោយហេតុថា ភាគីក្រុមហ៊ុនមិនបានចូលរួមដោះស្រាយតាមលិខិតអញ្ជើញលេខ ៥៧៩ កប/អក/កវ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១១ ហើយអ្នកផ្សះផ្សាយល់ឃើញថា គួរបញ្ជូនសំណុំរឿងនេះ ទៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីដោះស្រាយតាមនីតិវិធីច្បាប់។

ក្រុមប្រឹក្សាអាជ្ញាកណ្តាល បានទទួលសំណុំរឿងមិនសះជាចំនួន ១០ ចំណុចនេះ នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១១ តាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមមិនសះជាលេខ ៩២៦ កប/អក/វក ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១១ ។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកោះអញ្ជើញភាគីនិយោជក និងភាគីសហជីពសម្ព័ន្ធកម្មករខ្មែរមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ១០ ចំណុចនេះ នៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១១ វេលាម៉ោង០៨៖៣០នាទីព្រឹក។ ភាគីក្រុមហ៊ុនមិនបានមកចូលរួមសវនាការតាមការកោះអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ (អវត្តមានដោយគ្មានមូលហេតុ)។ ហើយភាគីសហជីពសម្ព័ន្ធកម្មករខ្មែរប្រចាំរោងចក្រ ដែលជាភាគីដើមបណ្តឹង ក៏មិនបានចូលរួមសវនាការតាមការកោះអញ្ជើញ(អវត្តមានដោយគ្មានមូលហេតុ)ដែរ គឺមានតែលោក មុំ បូណា និងលោក ឡុង សេរី ជាមន្ត្រី ដែលតំណាងឱ្យសហព័ន្ធសហជីពសម្ព័ន្ធកម្មករខ្មែរតែប៉ុណ្ណោះ ដែលបានមកចូលរួម។

លោក មុំ បូណា បានបញ្ជាក់ថា ភាគីកម្មករនិយោជិត(សហជីពសម្ព័ន្ធកម្មករខ្មែរប្រចាំរោងចក្រ)មិនបានធ្វើលិខិតផ្ទេរសិទ្ធិជូនពួកគាត់ទេ ហើយពួកគាត់ក៏មិនបានដឹងថា ថ្នាក់ដឹកនាំសហជីពទាំងបីនាក់នៅឯណាដែរ (លោក ឈួន ធឿន ជាប់ជាប្រធាន លោក ពុំ ចាន់ ជាប់ជាអនុប្រធាន និងលោក ឌឹម សុនុន ជាប់ជាលេខាធិការ) ពីព្រោះពុំអាចទាក់ទងថ្នាក់ដឹកនាំសហជីពទាំងបីនាក់នោះបាន ទន្ទឹមនឹងនេះដែរកម្មករនិយោជិតក៏ពុំមានធ្វើលិខិតផ្ទេរសិទ្ធិជូនទៅសហព័ន្ធដែរ។

ពួកគាត់មកចូលរួមសវនាការនេះ គឺដើម្បីសួរបញ្ជាក់ទៅក្រុមប្រឹក្សាអាជ្ញាកណ្តាលថា តើពួកគាត់ជាមន្ត្រីសហព័ន្ធសហជីពសម្ព័ន្ធកម្មករខ្មែរអាចធ្វើជាតំណាងឱ្យកម្មករនិយោជិតបានដែរឬទេ? ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបញ្ជាក់ថា បើពួកគាត់មិនមានលិខិតផ្ទេរសិទ្ធិពីថ្នាក់ដឹកនាំសហជីព ឬពីកម្មករនិយោជិតទេ គឺមិនមានសិទ្ធិតំណាងឱ្យភាគីកម្មករនិយោជិតបានទេ។

ចំណែកឯង ភាគីក្រុមហ៊ុនក៏មិនបានមកចូលរួមសវនាការតាមការអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលដែរ (អវត្តមានដោយគ្មានមូលហេតុ)។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងសម្រេចករណីគ្មានតំណាងភាគីកម្មករនិយោជិត (សហជីពសម្ព័ន្ធកម្មករខ្មែរ ប្រចាំរោងចក្រ) និងគ្មានតំណាងភាគីក្រុមហ៊ុនមកចូលរួមសវនាការនៅក្នុងសំណុំរឿងនេះ ដូចខាងក្រោម:

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក ៖ គ្មាន

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖

១- សារណាសង្ខេបនៃវិវាទការងាររបស់សហព័ន្ធសហជីពសម្ព័ន្ធកម្មករខ្មែរ គោរពជូន លោកប្រធានក្រុមប្រឹក្សាអាជ្ញាកណ្តាល ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១១។

២- សាលាកប័ត្រផ្ញើសេវា EMS ក្នុងប្រទេស ពីសហព័ន្ធសហជីពសម្ព័ន្ធកម្មករខ្មែរ ទៅលោកនាយកក្រុមហ៊ុន ហ្វុង ឈឹង ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១១ ។

៣- សេចក្តីជូនដំណឹងរបស់សហព័ន្ធសហជីពសម្ព័ន្ធកម្មករខ្មែរ ជំរាបជូន លោកនាយកក្រុមហ៊ុន ហ្វុង ឈឹង ឱ្យបានជ្រាបនូវការរៀបចំបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំសហជីពសម្ព័ន្ធកម្មករខ្មែរ ប្រចាំរោងចក្រ ហ្វុង ឈឹង ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១១ ។

៤- លិខិតអញ្ជើញរបស់នាយកដ្ឋានវិវាទការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អញ្ជើញ លោក-លោកស្រី ថ្នាក់ដឹកនាំសហជីពសម្ព័ន្ធកម្មករខ្មែរប្រចាំរោងចក្រ ហ្វុង ឈឹង លេខ ៥៧៨ កប/អក/វក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១១។

៥- បង្កាន់ដៃទទួលសំណុំរឿងរបស់នាកយកដ្ឋានវិវាទការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ពីសហជីពសម្ព័ន្ធកម្មករខ្មែរនៃក្រុមហ៊ុន ហ្វុង ឈឹង ស្តីពីសុំចុះបញ្ជិកាសហជីព ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ ២០១១ ។

៦- ពាក្យបណ្តឹងរបស់តំណាងសហជីពសម្ព័ន្ធកម្មករខ្មែរនៃរោងចក្រកាត់ដេរ ហ្វុង ឈឹង ព្រមទាំងកម្មករ កម្មការិនី គោរពជូន លោប្រធានសហព័ន្ធសហជីពសម្ព័ន្ធកម្មករខែរ ស្តីពីសុំលោកប្រធានជួយដោះស្រាយទុក្ខកង្វល់របស់កម្មករ-កម្មការិនីនៃរោងចក្រកាត់ដេរ ហ្វុង ឈឹង ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០១១ ។

៧- កំណត់ហេតុស្តីពីការសាកសួរព័ត៌មានពីតំណាងកម្មករនិយោជិតនៃក្រុមហ៊ុន ហ្វុង ឈឹង ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១១ ។

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ហ្វុង ឈឹង លេខ ៩២៦ កប/អក/វក ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១១ ។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ហ្វុង ឈឹង ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១១ ។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលេខ ៩៩៨ កប/អក/វក/លកអ. ចុះថ្ងៃទី១៨ ខែ សីហា ឆ្នាំ២០១១ ។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលេខ ៩៩៩ កប/អក/វក/លកអ. ចុះថ្ងៃទី១៨ ខែ សីហា ឆ្នាំ២០១១ ។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និង ភាគីនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖

ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចរកឃើញអង្គហេតុទាក់ទងនឹងការទាមទារនេះទេ ដោយហេតុថា សហជីពសម្ព័ន្ធកម្មករខ្មែរប្រចាំរោងចក្រ អវត្តមាននៅថ្ងៃសវនាការ ដោយគ្មានមូលហេតុ ហើយលោក មុំ បូណា និងលោក ឡុង សេរី មន្ត្រីសហព័ន្ធសហជីពសម្ព័ន្ធកម្មករខ្មែរ ដែលបានអញ្ជើញមកចូលរួមសវនាការ ក៏មិនមានលិខិតផ្ទេរសិទ្ធិពីសហជីពសម្ព័ន្ធកម្មករខ្មែរប្រចាំរោងចក្រ និងពីកម្មករនិយោជិត ដើម្បីទាមទារដែរ។ ចំណែកឯភាគីក្រុមហ៊ុនក៏មិនបានអញ្ជើញមកចូលរួមសវនាការដែរ។

**ហេតុផលនៃសេចក្តីសម្រេច**

នៅក្នុងសំណុំរឿងនេះ ភាគីដើមបណ្តឹងដែលទាមទារ គឺសហជីពសម្ព័ន្ធកម្មករខ្មែរប្រចាំរោងចក្រ។ ទាំងភាគីសហជីពមូលដ្ឋាន និងក្រុមហ៊ុន មិនបានអញ្ជើញមកចូលរួមសវនាការទេ គឺមានតែលោក មុំ បូណា និងលោក ឡុង សេរី មន្ត្រីសហព័ន្ធសហជីពសម្ព័ន្ធកម្មករខ្មែរតែប៉ុណ្ណោះ ដែលបានមកចូលរួម។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាករណីនេះ ដូចខាងក្រោមៈ

ប្រការ ២១ នៃប្រកាសលេខ ០៩៩ ចែងថា "*ក្នុងករណីភាគីណាមួយបានទទួលការអញ្ជើញត្រឹមត្រូវហើយ តែបែរជាខកខានមិនបានមកបង្ហាញខ្លួននៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាល ដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងពេលដែលភាគីនោះអវត្តមាន ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយចេញសេចក្តីបង្គាប់* "។

វិធាន ៤.៧ នៃឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ ចែងថា "*ប្រសិនបើភាគីណាមួយមិនបានមកបង្ហាញខ្លួន ឬមិនមានអ្នកតំណាងក្នុងដំណើរការអាជ្ញាកណ្តាល ក្រុមអាជ្ញាកណ្តាល អាចបន្តដំណើរការរបស់ខ្លួន ក្នុងអវត្តមាន របស់ភាគីនោះ ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយចេញសេចក្តីបង្គាប់។ ក្នុងករណីណាមួយ ក្រុមអាជ្ញាកណ្តាល*

*ត្រូវតែបំពេញតាមលក្ខខណ្ឌថា ភាគីវិវាទបានទទួលការជូនដំណឹងយ៉ាងត្រឹមត្រូវអំពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងនៃដំណើរការអាជ្ញាកណ្ដាល មុនពេលធ្វើសេចក្ដីសម្រេចរបស់ខ្លួន"* ។

តាមខ្លឹមសារនៃវិធាន ៤.៧ នៃវិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្ដាល ឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ខាងលើមានន័យថា ក្រុមប្រឹក្សាអាជ្ញាកណ្ដាលអាចបន្តដំណើរការ ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្ដាលដោយចេញសេចក្ដីបង្គាប់ ក្នុងករណីភាគីណាមួយមិនបានមកបង្ហាញខ្លួន ឬមិនមានអ្នកតំណាងក្នុងដំណើរការអាជ្ញាកណ្ដាល (អវត្តមានរបស់ភាគី) ។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលពិនិត្យឃើញថា លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាល បានជូនដំណឹងស្ដីពីការអញ្ជើញចូលរួមសវនាការទៅភាគីនិយោជក និងភាគីកម្មករនិយោជិតត្រឹមត្រូវហើយ ដែលចុះនៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១១។ គូភាគីទាំងពីរក៏ទទួលបានការជូនដំណឹងអំពីការកោះអញ្ជើញនេះបានត្រឹមត្រូវដែរ ។ ប៉ុន្តែ នៅថ្ងៃសវនាការ សហជីពសម្ព័ន្ធកម្មករខ្មែរប្រចាំរោងចក្រ ដែលជាភាគីដើមបណ្ដឹង ដែលមានសិទ្ធិតំណាងឱ្យកម្មករនិយោជិត ដែលជាសមាជិកសហជីពរបស់ខ្លួន ក៏ដូចជាកម្មករនិយោជិតដែលបានធ្វើការទាមទារនៅក្នុងសំណុំរឿងនេះ បែរជាមិនបានអញ្ជើញមកចូលរួមសវនការ (អវត្តមានដោយគ្មានមូលហេតុ) ហើយក៏ពុំបានធ្វើលិខិតផ្ទេរសិទ្ធិឱ្យលោក មុំ បូណា និងលោក ឡុង សេរី មន្ត្រីសហព័ន្ធសហជីពសម្ព័ន្ធកម្មករខ្មែរ ដែលបានអញ្ជើញមកចូលរួមសវនាការ ដើម្បីជួយដោះស្រាយវិវាទរបស់ពួកគាត់ឡើយ ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលធ្វើការពិចារណាបន្តថា តើលោក មុំ បូណា និងលោក ឡុង សេរី មន្ត្រីសហព័ន្ធសហជីពសម្ព័ន្ធកម្មករខ្មែរមានសិទ្ធិស្របច្បាប់ ដើម្បីដោះស្រាយវិវាទក្នុងនាមសហជីពសម្ព័ន្ធកម្មករខ្មែរ ប្រចាំរោងចក្រ និងសមាជិកសហជីពនៅក្នុងរោងចក្រ ហ្វុង ឈីង នេះ ដែរ ឬទេ ?

ប្រការ ១៩ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្ដីពីក្រុមប្រឹក្សាអាជ្ញាកណ្ដាលចែងថា "*ភាគីវិវាទអាចមកបង្ហាញខ្លួន នៅចំពោះមុខក្រុមអាជ្ញាកណ្ដាលដោយផ្ទាល់ខ្លួន ឬដោយមានអ្នកអម ឬតំណាងដោយមេធាវីដែលជាសមាជិកនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ឬដោយបុគ្គលផ្សេងទៀត ដែលបានទទួលការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីភាគីនោះ*" ។

ប្រការនេះ បញ្ជាក់ច្បាស់លាស់ថា អ្នកដែលមកតំណាងឱ្យភាគីវិវាទ ត្រូវទទួលការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីភាគីនោះ។ នៅក្នុងករណីនេះ សហជីពសម្ព័ន្ធកម្មករខ្មែរប្រចាំរោងចក្រ និងសមាជិកសហជីពដែលជាភាគីវិវាទ និងជាភាគីដើមបណ្ដឹងនៅក្នុងសំណុំរឿងនេះ មិនបានតែងតាំង និងផ្ទេរសិទ្ធិឱ្យ លោក មុំ បូណា និង លោក ឡុង សេរី ដើម្បីឱ្យជួយដោះស្រាយវិវាទការងារនេះឡើយ ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា លោក មុំ បូណា និងលោក ឡុង សេរី ពុំមានសិទ្ធិស្របច្បាប់ក្នុងការតំណាងឱ្យសហជីពមូលដ្ឋាន និងកម្មករនិយោជិត ដែលជាសមាជិកសហជីពក្នុងការដោះស្រាយសំណុំរឿងវិវាទការងារនេះទេ ។

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា ការដែលសហជីពសម្ព័ន្ធកម្មករខ្មែរប្រចាំរោងចក្រមិនបានមកបង្ហាញខ្លួន ឬមិនបានចាត់អ្នកតំណាង ក្នុងដំណើរការអាជ្ញាកណ្ដាលនេះ គឺសហជីពបានបោះបង់ការទាមទាររបស់ខ្លួន។

ជាទូទៅ ដើមបណ្តឹងមានកាតព្វកិច្ចផ្តល់ហេតុផល និងភស្តុតាង នៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីការពារបណ្តឹងរបស់ខ្លួន។ ប៉ុន្តែ ក្នុងសំណុំរឿងនេះ ភាគីសហជីពសម្ព័ន្ធកម្មករខ្មែរប្រចាំរោងចក្រដែលជាភាគីដើមបណ្តឹងមិនបានផ្តល់នូវហេតុផល និងភស្តុតាង ដើម្បីការពារបណ្តឹងរបស់ខ្លួនទេ។ ក្នុងករណី ភាគីដើមបណ្តឹងមិនមកបង្ហាញខ្លួន ឬចាត់អ្នកតំណាងក្នុងដំណើរការអាជ្ញាកណ្តាលធ្វើឱ្យភាគីបាត់បង់ឱកាស ក្នុងការផ្តល់ហេតុផល និងភស្តុតាង ដើម្បីការពារ និងគាំទ្រការទាមទាររបស់ខ្លួន។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលចាត់ទុកថា នេះជាការបោះបង់បណ្តឹងរបស់ខ្លួន។ ការសម្រេចចិត្តបែបនេះ គឺមិនបានបង្ហាញពីសុឆន្ទៈ ដោយសុទ្ធចិត្តរបស់ភាគីសហជីពសម្ព័ន្ធកម្មករខ្មែរ ក្នុងការយកវិវាទការងាររបស់ខ្លួនមកដោះស្រាយ នៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាលនោះឡើយ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបិទសំណុំរឿងលេខ ១០៦/១១-ហ៊ុង ឈឹង នេះ។

## សម្រេច និង បង្គាប់

- បិទសំណុំរឿងលេខ ១០៦/១១-ហ៊ុង ឈឹង ។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖

ឈ្មោះ ៖ **យូ សួនធី**

ហត្ថលេខា: ------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖

ឈ្មោះ ៖ **អាន វីរៈ**

ហត្ថលេខា: ------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល ៖

ឈ្មោះ ៖ **ម៉ែន ម៉ុនឈា**

ហត្ថលេខា: ------------------------------